# ឌុច សុំសាលក្រមសម្រេចឱ្យរួចខ្លួន និងការដោះលែងភ្លាមៗ

***សាស្ត្រាចារ្យ ដេវីដ សេហ្វហ្វឺ***

***ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ថ្ងៃចុងក្រោយនៃការបញ្ចប់ការសួរដេញដោលនៅក្នុងតុលាការកាត់ទោសរបស់ កាំង ហ្គេចអ៊ាវ (ហៅ ឌុច) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គឺជាការបញ្ចប់មួយដ៏គួរឲ្យភ្ញាក់ផ្អើល និងមានលក្ខណៈតានតឹងសម្រាប់តុលាការកាត់ទោសប្រវត្តិសាស្ត្រនៃរយៈកាលបីទសវត្សរ៍ បន្ទាប់ពីឧក្រិដ្ឋកម្មនៃភាពសាហាវឃោរឃៅរបស់របប ប៉ុល ពត ។ នៅថ្ងៃនេះ កំហុសរបស់ ឌុច ដែលបានសារភាព ត្រូវបានប្រែក្លាយទៅជាការស្នើសុំឲ្យរួចទោស ហើយសេចក្តីរំពឹងទុកនៃការឃុំខ្លួនរបស់ ឌុច សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិនៅមន្ទីរស-២១ បែរជាត្រូវបានរុញច្រានដោយការទាមទាររបស់ ឌុច ឲ្យខ្លួនត្រូវបានដោះលែង ដើម្បីធ្វើឲ្យខ្លួនឯងទទួលបានសិទ្ធិសេរីភាពម្តងទៀត ។ ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណីនិងប្រជាជនកម្ពុជារាប់រយនាក់ដែលអង្គុយនៅក្នុងសាលសាធារណ បានឃើញនូវទស្សនីយភាពនៃបុកពារឆ្មើងឆ្មៃនិងក្រអើតក្រទមដ៏គួរឲ្យភ្ញាក់ផ្អើលមួយ ដែលអាចឆ្លុះបង្ហាញថាជាយុត្តិសាស្ត្រការពារខ្លួនដ៏ឈ្លាសវៃនៅកាលៈទេសៈសំខាន់នេះ ។ ប៉ុន្តែវាមើលទៅ គឺហាក់បីដូចជាការរំលោភបំពានមួយដែលក្លាយជាការវាយប្រហារដោយផ្ទាល់ទៅលើគោលបំណងទាំងស្រុងរបស់យុត្តិធម៌អន្តរជាតិ និងការថែរក្សាការចងចាំទៅវិញទេ ។

## *សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត*

នៅក្នុងថ្ងៃនេះ សេចក្តីជំទាស់ បានចាប់ផ្តើមបន្តភ្លាមៗដោយសហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត ដែលបានលើកឡើងពីសេចក្តីជំទាស់មួយប្រឆាំងតបតនឹងមេធាវីការពារក្តីចំពោះករណីជាច្រើន ។ វីលៀម ស្មីត បានលើកឡើងពីការមិនទទួលយកចំពោះការចោទប្រកាន់របស់មេធាវីការពារក្តីដែលថា ព្រះរាជអាជ្ញាបាន«កំពុងប្រើប្រាស់រឿងមិនមែនជាការពិត» នៅក្នុងរឿងក្តីរបស់ខ្លួន ដើម្បីប្រឆាំងនឹង ឌុច ។ លោកបានបង្ហាញប្រាប់ចៅក្រមពីការដាក់សេចក្តីសន្និដ្ឋានទាំងអស់របស់ព្រះរាជអាជ្ញា រួមមានការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរចុងក្រោយ ដែលមានចំនួន១៦០ទំព័រ ដោយភ្ជាប់ជាមួយ

នឹងឯកសារយោងចំនួន១០០០ ។ វីលៀម ស្មីត បានមានយោបល់ថា "តុលាការគួរតែពិចារណាលើភស្តុតាងជាជាងការបរិយាយ" ។ លោកទទួលស្គាល់ពីកិច្ចសហប្រតិបត្តិការដែលគ្មានលក្ខខណ្ឌកំណត់របស់ ឌុច នៅក្នុងទំព័រទី៦នៃសេចក្តីសន្និដ្ឋានបញ្ចប់ក្រោយរបស់លោកដោយបន្ថែមថា ឌុច បានសហប្រត្តិបតិជាទូទៅនិងបានបង្ហាញពីការសុំទោស ។ ដូច្នេះការប្រព្រឹត្តិបែបនេះគួរតែក្លាយជាកត្តាសម្រាលទោសនៅក្នុងសេចក្តីសម្រេចកាត់ទោស ។ ការចោទប្រកាន់របស់មេធាវីការពារក្តី ដែលថាគ្មានការទទួលស្គាល់បែបនេះនោះ "គឺជារឿងមិនពិត និងប្រាកដជាមិនមានភាពត្រឹមត្រូវឡើយ" ។

វីលៀម ស្មីត បាននិយាយទៅកាន់ចៅក្រមថា "អ្នកត្រូវបានធ្វើឲ្យយល់ខុសដោយសារតែមេធាវីការពារក្តី ។ សេចក្តីសន្និដ្ឋានរបស់គេ គឺគ្មានអ្វីដែលបង្ហាញពីស្ថានភាពសម្រាលទោសឡើយ ។ នៅក្នុងតុលាការកាត់ទោស និងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន មេធាវីការពារក្តី បានទទួលស្គាល់ថា ឌុច នឹងសុំទទួលកំហុស មិនមែនសុំឲ្យរួចទោសនោះទេ ប៉ុន្តែកាលពីម្សិលមិញ ឌុច បានស្នើសុំឲ្យរួចទោសដោយផ្អែកលើការសហប្រតិបត្តិការរបស់ ឌុច ជាមួយនឹងអាជ្ញាធរ ។ តម្រូវការបែបនេះត្រូវតែកែតម្រូវ ។ មេធាវីការពារក្តីកំពុងតែបោះបង់ចោលកូនក្តីរបស់ខ្លួន ហើយនេះគឺជាការប្រព្រឹត្តិមួយដែលមិនសមហេតុផល ។ ប្រសិនបើជនត្រូវចោទបានបង្គាប់ មេធាវីការពារក្តីឲ្យស្នើសុំឲ្យរួចទោស នោះមានន័យថាជនត្រូវចោទមិនគួរទទួលបានអត្ថប្រយោជន៍អ្វី ពីកត្តាសម្រាលទោសណាមួយឡើយសម្រាប់ការកាត់ទោសរបស់ខ្លួន" ។

យ៉ាងណាមិញ វីលៀម ស្មីត បានធ្វើការពិចារណាយ៉ាងល្អិតល្អន់លើស្ថានភាពខុសប្លែកមួយ ។ "ខ្ញុំជឿថា មេធាវីការពារក្តី បានធ្វើបែបនេះដោយគ្មានការបង្គាប់បញ្ជាពីកូនក្តីរបស់ខ្លួនឡើយ ។ ដូច្នេះថ្ងៃនេះ ចៅក្រម គួរតែដោះស្រាយបញ្ហានេះភ្លាមៗ បើមិនដូច្នោះទេជនត្រូវចោទនឹងចាត់ទុកថា ខ្លួនទទួលបានភាពលំអៀង និងអាចប្តឹងឧទ្ធរណ៍សម្រាប់សាលក្រម ហើយនឹងអាចនិយាយថាមេធាវីការពារក្តីរបស់ខ្លួន មិនបានធ្វើតាមសេចក្តីបង្គាប់របស់ខ្លួនទេ ជាហេតុដែលយើងនឹងធ្វើការដោះស្រាយបញ្ហានេះសារជាថ្មីម្តងទៀត.... ។ តើ ឌុច បានស្នើសុំអ្វីការសុំទទួលស្គាល់កំហុស ឬការសុំឲ្យរួចទោស? ការឆ្លើយតបនឹងសំណួរនេះអាចនឹងគេចផុតពីសំណូមពរដែល ឌុច អាចលើកឡើងនាពេលអនាគតបាន" ។

ជំហានបន្ទាប់ គឺព្យាយាមលាតត្រដាងពីខ្លឹមសារនៃការដាក់សេចក្តីសន្និដ្ឋាន លើការសុំឲ្យរួចទោសរបស់ ឌុច ប្រសិនបើការដាក់សេចក្តីសន្និដ្ឋាននេះ គឺប្រាកដថាជាអ្វីដែល ឌុច បានធ្វើមែននោះ ។ វីលៀម

ស្មឹត បាននិយាយថា មេធាវីការពារក្ដីអះអាងថាការដែល ឌុច ទទួលបានអត្ថប្រយោជន៍ពីការលើកលែងទោសដែលមិនមែនស្ថិតនៅក្រោមយុត្តាធិការខក្រិដ្ឋកម្មជាតិនោះ គឺមិនមានជាប់ពាក់ព័ន្ធនឹងភស្តុ-តាងណាមួយនៃការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឡើយ ។ ហើយ ឌុច មានភាពរីករាយជាមួយនឹងសិទ្ធិការការពារខ្លួនដ៏ពេញលេញ ពីព្រោះថា ឌុច បានគោរពតាមបញ្ជារបស់ថ្នាក់លើតែប៉ុណ្ណោះ ។ មេធាវីការពារក្ដីអន្តរជាតិបានទទួលស្គាល់ថាអ្វីៗត្រូវបានផ្លាស់ប្ដូរកាលពីថ្ងៃព្រហស្បតិ៍ ក្នុងកាលៈទេសៈដែលកូនក្ដីរបស់លោកបានអះអាងថាខ្លួន«គ្មានទោស» ឬចំណែកឯលោកវិញបានសុំការសម្រាលទោស ។ អ្វីដែលប្រាកដនោះគឺថាមេធាវីការពារក្ដីនិងកូនក្ដីរបស់ខ្លួនកំពុងតែស្នើរសុំឲ្យរួចទោស ប៉ុន្តែសំណួរ គឺថាតើមេធាវីការពារក្ដីកំពុងតែបំពេញតួនាទីតាមសេចក្ដីបង្គាប់បញ្ជាក្រោយពីរយៈពេលជាច្រើនខែ ក្នុងការធ្វើជាតំណាងឲ្យការសុំទទួលស្គាល់កំហុសសម្រាប់ខក្រិដ្ឋកម្មនៅមន្ទីរស-២១ឬក៏យ៉ាងណា? វីលៀម ស្មឹត បានតបតថា «ទង្វើរបែបនេះ គឺពិតជាមិនអាចទទួលយកបានទេនៅក្នុងតុលាការ» ។

បន្ទាប់មកទៀត វីលៀម ស្មឹត បាននិយាយពីចំណុចពិសេសខ្លះៗដែលបានលើកឡើងដោយមេធាវីការពារក្ដីកាលពីម្សិលមិញ ។ លោកបាននិយាយថា ច្បាប់លើកលែងទោសឆ្នាំ១៩៩៨ មិនត្រូវបានអនុវត្តទេ ពីព្រោះថាច្បាប់របស់ អ.វ.ត.ក បានដកច្បាប់នេះចេញជាធរមានរួចទៅហើយ ។ ហើយបើទោះបីជាច្បាប់របស់ អ.វ.ត.ក មិនទាន់បានដកច្បាប់នេះចេញក៏ដោយ ក៏ច្បាប់លើកលែងទោសមិនមានជាប់ពាក់ព័ន្ធនឹងជនត្រូវចោទនេះដែរ ។ បន្ថែមលើនេះ ការដាក់សេចក្ដីសន្និដ្ឋានបន្ទាន់របស់មេធាវីការពារក្ដីទាក់ទិននឹងសេចក្ដីជំទាស់នេះ មានភាពយឺតយ៉ាវដល់ទៅមួយឆ្នាំកន្លះហើយ ដែលសេចក្ដីសន្និដ្ឋាននេះ គួរតែត្រូវបានដាក់ជូនស្របពេលជាមួយនឹងនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងទី៨៩ ។ លើសពីនេះ មាត្រាទី២៩នៃច្បាប់របស់ អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា ការបញ្ជារបស់ថ្នាក់លើគ្មានការការពារខ្លួនទេ ដែលនេះបានឆ្លុះបញ្ចាំងពីយុត្តិសាស្ត្រអន្តរជាតិដែលបានរៀបរៀងឡើងយ៉ាងល្អសម្រាប់ខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងខក្រិដ្ឋកម្មសង្គ្រាម ។

## លោក ការីម ខាន មានមតិយោបល់

ក្រោយពី វីលៀម ស្មឹត អង្គុយចុះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ការីម ខាន បានក្រោយឈរ និងស្នើឲ្យចៅក្រមធ្វើការដោះស្រាយទៅតាមសំណូមពររបស់ វីលៀម ស្មឹត សម្រាប់សេចក្ដី

បន្ទាប់បញ្ចប់ពី ឌុច ចំពោះការស្នើសុំដែល ឌុច បានធ្វើឡើង។ ចៅក្រមគួរតែសួរ ឌុច ភ្លាមៗដើម្បីឲ្យសហព្រះរាជអាជ្ញាអាចឆ្លើយតបទៅវិញសេចក្តីបន្ទាប់បញ្ចប់របស់ ឌុច បាន។ លោកបានប្រឈមមុខនឹងភាពស្ងប់ស្ងាត់ពីចៅក្រម បន្ទាប់មកសហព្រះរាជអាជ្ញាជាតិ ជា លាង ត្រូវបានអញ្ជើញឲ្យមានមតិបន្តលើសេចក្តីជំទាស់របស់ព្រះរាជអាជ្ញា។ ការីម ខាន អង្គុយត្រង់ខ្លួនអស់រយៈពេលជាច្រើននាទីរង់ចាំការឆ្លើយតបខ្លះៗចំពោះសំណូមពររបស់លោក ប៉ុន្តែការឆ្លើយតបមិនបានកើតឡើងទេ រហូតមកដល់ដំណើរការនីតិវិធីនៅពេលព្រឹក។

## សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាជាតិ ជា លាង

ជា លាង បានចាប់ផ្តើមមានប្រសាសន៍ដោយនិយាយថា មេធាវីការពារក្តីមិនគួរព្យាយាមស្វែងរកគំនុំគុំគួននោះទេ ប៉ុន្តែគួរតែស្វែងរកយុត្តិធម៌តាមកាតព្វកិច្ចរបស់ខ្លួននៅចំពោះមុខតុលាការ។ «តើឧក្រិដ្ឋកម្ម បានកើតមានឡើងនៅមន្ទីរស-២១មែនឬទេ ហើយតើនរណាជាអ្នកទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ»? មេធាវីការពារក្តី មិនបាននាំយកភស្តុតាងដែលបញ្ជាក់ពីភាពគ្មានពិរុទ្ធភាពមកបង្ហាញសម្រាប់កូនក្តីរបស់ខ្លួន និងឧក្រិដ្ឋកម្មទាំងនោះឡើយ។ លោកស្រីបានលើកឡើងពីចំណុចរបស់ វីលៀម ស្មិត ម្តងទៀតថា ៖ «តើនេះគឺជាសំណូមពររបស់មេធាវីការពារក្តីដើម្បីសម្រាលការកាត់ទោសរបស់ ឌុច ឬដើម្បីឲ្យ ឌុច រួចទោស»? ។ លោកស្រីបាននិយាយថា ពេលវេលា បានកន្លងផុតទៅហើយក្នុងការលើកឡើងពីបញ្ហាដែលរៀបរាប់ដោយមេធាវីការពារក្តីកាលពីម្សិលមិញនោះ។ ជា លាង បានអះអាងថា ឌុច គឺពិតជាជនដែល«មានទំនួលខុសត្រូវខ្ពស់»សម្រាប់ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ដូច្នេះ ការពន្យឺកអាជ្ញាយុកាលសម្រាប់បទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ពិតជាមានលក្ខណៈស្របច្បាប់ទាំងស្រុង។ នេះក៏ដោយសារតែឧក្រិដ្ឋកម្មនៃការសម្លាប់មនុស្សដោយខុសច្បាប់ និងការធ្វើទារុណកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពិតជាបានកើតមានឡើងប្រាកដមែននៅក្នុងអំឡុងពេលប្រតិបត្តិការរបស់មន្ទីរស-២១។ ដូច្នេះ គោលការណ៍នៃនីត្យានុកូលភាព មិនត្រូវបានរំលោភបំពានដោយសកម្មភាពរបស់រដ្ឋសភាក្នុងការពន្យឺកអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មរយៈពេល៣០ឆ្នាំបន្ថែមបែបនេះទេ។ តាមពិតក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបញ្ហានេះកាលពីឆ្នាំ២០០១ និងបានចេញសេចក្តីសម្រេចពីរ ដែលបានដាក់ការពន្យឺកអាជ្ញាយុកាលឲ្យមានសុពលភាព ហើយក៏គ្មានការកោះហៅសម្រាប់សេចក្តីសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សាដែរ។ យ៉ាងណាមិញ ឧក្រិដ្ឋកម្មក៏មិនត្រូវបានផ្លាស់ប្តូរអ្វីដែរ។ ការពង្រឹងច្បាប់របស់ អ.វ.ត.ក ក៏បានរំលោភ

បំពានលើគោលការណ៍របស់សកម្មភាពដែលមិនត្រឡប់មកវិញម្តងទៀត ។ ឌុច គួរតែបានដឹងថា ការសម្លាប់និងការធ្វើទារុណ្ណកម្មលើអ្នកទោសលើសពី១២,០០០នាក់ គឺជាការប្រព្រឹត្តខុសច្បាប់ ។ តាមពិតទៅ ឌុច បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការធ្វើកសិណសាក្សីកាលពីមុនថា ខ្លួនបានដឹងពីភាពខុសច្បាប់នៃរបបនេះ ។ ជាចុងក្រោយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចរាល់ហើយចំពោះការដាក់បញ្ចូលការសម្លាប់ និងការធ្វើទារុណ្ណកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ចូលទៅក្នុងមាត្រាទី៣ នៃច្បាប់ អ.វ.ត.ក ។

ជា លាង បានរៀបរាប់ដើម្បីធ្វើឲ្យសេចក្តីជំទាស់ដ៏សំខាន់របស់មេធាវីការពារក្តីមិនសមហេតុផលថា ឌុច កំពុងតែត្រូវបានធ្វើជាអ្នកទទួលរងកំហុសសម្រាប់ឧក្រិដ្ឋកម្មរបស់អ្នកដទៃ ។ បានលើកឡើងពីតុលាការកាត់ទោសរបស់ លូប៉ាងហ្គា នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ នៅពេលដែល លូប៉ាងហ្គា ព្រមចុះចូលជាមួយនឹងតុលាការព្រហ្មអន្តរជាតិ ជាមួយគ្នានេះ លោកក៏ត្រូវបានចោទប្រកាន់ពីបទជាជនត្រូវចោទដែលរងកំហុស ដែលជាការចោទប្រកាន់មួយដែលត្រូវបានជំទាស់ភ្លាមៗនៅក្នុងតុលាការនោះ ។ នៅតុលាការនេះ អង្គបុរេជំនុំជម្រះធ្វើការពិនិត្យតែហេតុការណ៍របស់មន្ទីរស-២១តែប៉ុណ្ណោះ មិនមែនឧក្រិដ្ឋកម្មទាំងអស់ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ លោកស្រីបាននិយាយថាឧក្រិដ្ឋកម្មរបស់មន្ទីរស-២១ ត្រូវបានរៀបចំជាឯកសារបានយ៉ាងល្អ និងចង្អុលបង្ហាញដោយភស្តុតាងគ្រប់គ្រាន់ ។ តាមពិត “ឌុច បានសម្រេចថាមានកំហុសរួចទៅហើយសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ” ។

ជា លាង បានបន្តទៀតថា ឌុច គឺជាជនដែលនៅក្នុងចំណោមអ្នកដែលមានឋានៈខ្ពស់ និងមានទំនួលខុសត្រូវក្នុងរបប ប៉ុល ពត ។ ឌុច មានទំនួលខុសត្រូវសម្រាប់ការធ្វើទារុណ្ណកម្ម និងការសម្លាប់ ។ មន្ទីរស-២១ គឺជាគុកសន្តិសុខមួយដ៏សំខាន់ទូទាំងប្រទេស និងបានប្រតិបត្តិការដោយការទាក់ទងផ្ទាល់ជាមួយនឹងគណៈកម្មាការអចិន្ត្រៃយ៍ ។ គោលបំណងនៃមន្ទីរស-២១ គឺដើម្បីបោសសម្អាតខ្មាំងបុគ្គលិកផ្ទៃក្នុង និងសមាជិកបក្សកុម្មុយនីស្តកម្ពុជាតាមរយៈការចាប់ខ្លួនការឃុំឃាំង ការធ្វើ ទារុណ្ណកម្ម និងការស្លាប់លើអ្នកទោស ។ ឌុច បានបញ្ជាឲ្យមានការចាប់ខ្លួននិងការសម្លាប់ ។ ឌុច មានអំណាចក្នុងការចាប់ខ្លួន ដែល ឌុច បានអនុវត្តដោយឯកឯងនៅក្នុងកំឡុងពេលនោះ ។ ឌុច ទទួលបានអ្នកទោសពីក្រសួងទាំងអស់របស់របបនេះ និងបានប្រើប្រាស់ជំនាញដ៏អស្ចារ្យក្នុងការចាប់ខ្លួនមនុស្ស ។ ជា លាង បាននិយាយថា “ឌុច គឺជាឧក្រិដ្ឋជនពិតប្រាកដមែន” ។ “ឌុច គឺស្ថិតនៅពីក្រោយឧក្រិដ្ឋកម្មទាំងនេះ ។ ឌុច

គឺជាអ្នកចាត់ចែងមន្ទីរស-២១ និងបានដឹកនាំតួនាទីទាំងស្រុងរបស់មជ្ឈមណ្ឌលនេះ ។ ឌុច គឺជាជនដែលមានឋានៈខ្ពស់បំផុតក្នុងចំណោមជនដទៃទៀតដែល“មានទំនួលខុសត្រូវខ្ពស់” ។

ជា លាង បានបន្តមានប្រសាសន៍ទៀតថា ឌុច បានដឹងពីការកើតមានឡើងនៃជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ ឌុច ក៏បានដឹងថា សុន សេន ត្រូវតែទៅធ្វើសមរភូមិមុនថ្ងៃនោះ ។ តាមពិតទៅ សុន សេន បាននិយាយគ្រោះៗប្រាប់ ឌុច ពីជម្លោះនោះ ។ ជាមួយគ្នានេះ តាមរយៈការចាប់ខ្លួនជនជាតិវៀតណាម និងការសួរចម្លើយជនជាតិវៀតណាមទាំងនេះ ឌុច អាចដឹងពីជម្លោះប្រដាប់អាវុធនេះប្រាកដណាស់ ។

ជា លាង បាននិយាយថា ឌុច មិនមានភាពស្មោះត្រង់ចំពោះការបង្ហាញពីវិប្បដិសាវីរបស់ខ្លួនឡើយ ។ ប៉ុន្តែ ឌុច បានសហការជាមួយនឹងអង្គបុរេជំនុំជម្រះ និងបានធ្វើការបកស្រាយដែល ឌុច បានទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងអស់ទាំងក្នុងបរិបថផ្នែកច្បាប់ និងផ្នែកផ្លូវអារម្មណ៍ ។ ប្រសិនបើ ឌុច គ្រាន់តែរក្សានូវការសហការនិងការបង្ហាញពីវិប្បដិសារីដ៏ស្មោះត្រង់នេះបាននោះ ជនរងគ្រោះប្រហែលជាអាចទទួលយកការសុំទោសរបស់ ឌុច បាន ។ ប៉ុន្តែការធ្វើបែបនេះ មិនបានកើតមានឡើងឡើយ ។

## វីលៀម ស្មីត បានឡើងមានយោបល់ម្តងទៀត

វីលៀម ស្មីត បានឡើងមានយោបល់ម្តងទៀតដើម្បីធ្វើបទបង្ហាញពីសមាសធាតុចុងក្រោយនៃសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា ។ លោកបាននិយាយឡើងវិញនូវបញ្ហាដ៏ស្មុគស្មាញក្នុងថ្ងៃនេះ ។ “មេធាវីការពារក្តីសុំការរួចទោស ។ ប្រសិនបើ ឌុច មិនអនុញ្ញាតឲ្យរួចទោសនោះ មេធាវីការពារក្តីចង់ឲ្យការដាក់ទណ្ឌកម្មមានរយៈពេលចាប់ពី១៧ទៅ២០ឆ្នាំ ។ ដោយចង់ចាំនៅក្នុងគំនិតពីវិសាលភាពដ៏ធំធេងនៃឧក្រិដ្ឋកម្មទាំងនេះ យុទ្ធសាស្ត្ររបស់មេធាវីការពារក្តីបង្ហាញពីទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្ម ដែលពិតជាមិនពេញលក្ខណៈ ។ វាមិនបានឆ្លុះបង្ហាញពីអ្វីដែលច្បាប់អន្តរជាតិបានតម្រូវឲ្យមានសម្រាប់ឧក្រិដ្ឋកម្មដែលមានទំហំធំបែបនេះទេ ។ បន្ទាប់មកទៀត វីលៀម ស្មីត បានធ្វើការញែកលក្ខណៈខុសដោយឡែករបស់តុលាការកាត់ទោសរបស់ Dragan អុប្រេំណូវិច ចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការកាត់ទោសរបស់ ឌុច ជាកិច្ច ឆ្លើយតបនឹងការខិតខំបកស្រាយរបស់មេធាវីការពារក្តីអន្តរជាតិ ហ្វ្រង់ស៊័រ រូ ក្នុងការទាញយកការប្រៀបធៀបដ៏មានប្រយោជន៍ពី

តុលាការនេះកាលពីម្សិលមិញ ។ “ខ្ញុំបានធ្វើការនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី” វីលៀម ស្មីត បានក្រើនរំលឹកប្រាប់អ្នកគ្រប់គ្នា ។ “អូប្រ៊ីណូវិច គឺពិតជាមានលក្ខណៈខុសគ្នាយ៉ាងដាច់ស្រឡះពីករណីប្រឆាំងនឹងជនត្រូវចោទ ។ អូប្រ៊ីណូវិច គឺជាមន្ត្រីយោធាក្នុងការដើរតួជាតួអង្គដ៏សំខាន់នៅមុនពេលសង្គ្រាមបានកើតឡើង ។ ឌុច បានធ្វើកិច្ចការធ្វើទារុណកម្ម និងសម្លាប់របស់ខ្លួនអស់រយៈពេលរាប់ឆ្នាំមកហើយ ។ ឌុច បាននិយាយថាកាលពីដើមឆ្នាំ១៩៧១ “ខ្ញុំមិនអាចទ្រាំទ្រនឹងភាពបោកប្រាស់ទេ ដូច្នេះខ្ញុំនឹងវាយអ្នកទាំងនោះដល់ស្លាប់” ។ ផ្ទុយទៅវិញ អូប្រ៊ីណូវិច បានប្រព្រឹត្តសកម្មភាពរបស់ខ្លួនក្នុងរយៈពេលបីឆ្នាំ កាលពីឆ្នាំ១៩៩៥នៅ Srebrenica ។ អូប្រ៊ីណូវិច មិនមានភាពសកម្មក្នុងការបំពេញតួនាទីរបស់ខ្លួន ឡើយចំពោះការបញ្ជាឲ្យកូនចៅរបស់ខ្លួនចូលរួមក្នុងការប្រតិបត្តិការសម្លាប់លក្ខណៈទ្រង់ទ្រាយធំ ។ ប៉ុន្តែ នៅពេលដែលការស៊ើបអង្កេតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត យូហ្គោស្លាវី បានចាប់ផ្តើមដំណើរការ លោក អូប្រ៊ីណូវិច បានសហការយ៉ាងពេញទំហឹង ដោយអនុញ្ញាតឲ្យមន្ត្រីស៊ើបអង្កេតចូលជួបនៅក្នុងបន្ទប់ការិយាល័យរបស់លោក ។ សម្រាប់ ឌុច វិញ ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ មានរយៈពេលបីឆ្នាំកន្លះដែលមានអ្នកស្លាប់បាត់បង់ជីវិតលើសពី ១២,០០០នាក់ ។ ឌុច មិនអាចប្រៀបប្រដូចនឹងលោក អូប្រ៊ីណូវិច បានឡើយ ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះនេះគួរតែផ្តល់ឲ្យ ឌុច នូវការកាត់ទោសទ្វេរជាបីនឹងការកាត់ទោសដែលលោក អូប្រ៊ីណូវិច ទទួលបាន” ។

សម្រាប់សេចក្តីអះអាងចំពោះករណី អាល់ប៊ឺត ស្ពៀរ ដូចដែលបានលើកឡើងដោយមេធាវីការពារក្តីហ្វ្រង់ស័រ រូ, វីលៀម ស្មីត បាននិយាយថា ឌុច បានអនុវត្តគោលនយោបាយរបស់របប ប៉ុល ពត ដោយស្ម័គ្រស្មោះ ។ ប៉ុន្តែ អាល់ប៊ឺត ស្ពៀរ គឺខុសពី ឌុច ។ អាល់ប៊ឺត ស្ពៀរ មានសតិសម្បជញ្ញៈ និងពិតជាបានបញ្ជាមនុស្សរបស់ខ្លួនមិនឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រភេទទាំងអស់នោះមែន ។ គាត់គឺជាបុរសតិចតួចបំផុតដែលបានប្រាប់ អ៊ីត្លែរ ថារបបរបស់ អ៊ីត្លែរ កំពុងតែឈានដល់ទីបញ្ចប់ហើយ ។ គាត់បានការពាររារាំងរដ្ឋាភិបាលដោយចេតនា ដើម្បីឲ្យរដ្ឋាភិបាលនេះរួចផុតពីគ្រោះថ្នាក់មហន្តរាយ ។ ឌុច បានដឹងថា ៩០ភាគរយនៃជនរងគ្រោះរបស់ខ្លួនគឺជាមនុស្សគ្មានកំហុស ។ ឌុច បានទទួលស្គាល់កំហុសរបស់ខ្លួន ប៉ុន្តែមិនបានផ្តល់ភស្តុតាងដែលបញ្ជាក់ថាខ្លួនបានគេចវេសពីការទទួលបញ្ជានោះទេ ។ តើ ឌុច គឺជាអ្នកភាគីដ៏តូចតាចម្នាក់មែនដែរឬទេ? តើ ឌុច ត្រូវតែប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះឬ? តើ ឌុច អាចកាត់បន្ថយភាពឈឺចាប់ និងទុក្ខលំបាកវេទនានៃជនរងគ្រោះរបស់ខ្លួនបានដែរឬទេ? ឌុច បានធ្វើកសិណសាក្សីថា ឌុច បានហ៊ឹកហាត់អ្នកសួរចម្លើយ និងហ៊ានធ្វើឲ្យអ្នកទាំងនោះក្លាយជា

មនុស្សសាហាវឃោរឃៅ។ អំពើព្រៃផ្សៃដែល ឌុច បានបង្កឡើងនៅមន្ទីរស-២១ បានកើនឡើងកាន់តែច្រើន ទូទាំងសង្គមកម្ពុជាដោយសារតែឈ្មោះដែល ឌុច បានដកស្រង់ចេញពីការសួរចម្លើយ បណ្ដាលឲ្យមានការចាប់ខ្លួន ការធ្វើទារុណ្ណកម្ម និងការសម្លាប់កាន់តែច្រើនឡើង។

វីលៀម ស្មីត បាននិយាយថា ឌុច ត្រូវបានសួរថាតើ ឌុច គឺជាអ្នកអនុវត្តដ៏មានភាពស្មោះស្ម័គ្រម្នាក់ចំពោះថ្នាក់លើរបស់ខ្លួនដែរឬទេ។ ឌុច បានឆ្លើយថា «បាទ!ខ្ញុំគឺជាអ្នកអនុវត្តដ៏មានភាពស្មោះស្ម័គ្រម្នាក់មែន»។ វីលៀម ស្មីត បានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានផ្ដល់ឱកាសឲ្យ ឌុច ពីរថ្ងៃមុនដើម្បីធ្វើការសុំទោស។ ក្រៅពីការសុំឲ្យរួចទោសមក ឌុច បានឲ្យមេធាវីការពារក្ដីរបស់ខ្លួននិយាយថា ឌុច គ្រាន់តែជាភាគីតូចតាចរបស់អង្គការតែប៉ុណ្ណោះ។ ប៉ុន្តែ ឌុច នេះ ហើយគឺជាអ្នកដែលស្នើសុំឲ្យមានការធ្វើទារុណ្ណកម្ម និងចាប់ខ្លួនទៅកាន់ថ្នាក់លើ។ ឌុច មិនបានជ្រើសរើសយកឱកាសដើម្បីរត់គេចខ្លួនទេ។ ប៉ុន្តែ វីលៀម ស្មីត បានអះអាងថាអ្វីដែលរារាំងដល់រឿងក្ដីរបស់ ឌុច គឺទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយ សុន សេន។ ឌុច បាននិយាយប្រាប់អង្គសវនាការថា «នេះគឺជាសំណួរដែលខ្ញុំកំពុងតែរង់ចាំ»។ ខ្ញុំមានការគោរពកោតខ្លាច និងស្មោះស្ម័គ្រយ៉ាងខ្លាំងលើ សុន សេន។ សុន សេន បានធ្វើឲ្យ ឌុច មានឋានៈខ្ពស់តាំងពីមន្ទីរម-១៣ និងមន្ទីរស-២១។ បន្ថែមលើនេះ ឌុច ថែមទាំងបានរស់នៅជាមួយនឹង សុន សេន អស់រយៈពេល១៥ឆ្នាំក្រោយពីការដួលរំលំនៃរបប ប៉ុល ពត។

វីលៀម ស្មីត ចាប់ផ្ដើមមានភាពរំជើបរំជួល។ «ស្អីគេ! ឌុច ច្បាស់ជាលេងសើចហើយ។ ប្រសិនបើមិនដូច្នោះទេ នោះគឺជាការកំហុកទាំងស្រុង។ ឌុច បានចូលក្នុងតុលាការ ប៉ុន្តែ ឌុច មិនបានប្រឈមមុខនឹងអ្វីដែល ឌុច ធ្លាប់បានធ្វើ ប្រហែលជានៅក្នុងសេចក្ដីថ្លែងការចុងក្រោយ ឌុច នឹងងាយទៅរកដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិយាយថា «ខ្ញុំជឿជាក់លើបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំជឿថាបក្សកុម្មុយនីស្តកម្ពុជាគឺជាយានមួយដែលនាំមកនូវទីបញ្ចប់»។ តើ ឌុច អាចមានមោទនៈភាពចំពោះចៅហ្វាយនាយរបស់ខ្លួនដែលបានបញ្ជាឲ្យធ្វើទារុណ្ណកម្ម និងសម្លាប់អស់រយៈពេលជាច្រើនឆ្នាំបែបនេះដោយរបៀបណាទៅ»?

វីលៀម ស្មីត បានបន្តទៀតថា «រឿងក្ដីនេះ គឺមានមនុស្សប្រមាណ១២,០០០នាក់ត្រូវបានធ្វើទារុណ្ណកម្ម និងសម្លាប់យ៉ាងសាហាវឃោរឃៅ។ ដូច្នេះ វាមិនអាចក្លាយជាការកាត់ទោសដែលមានកម្រិតស្រាលបានទេ។ ចៅក្រមត្រូវតែសម្រេចកាត់ទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៤០ឆ្នាំ»។

វីលៀម ស្មីត បានកត់សម្គាល់ពីគោលបំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលចង់បានការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ លោកបានពន្យល់ថា តុលាការត្រូវតែកាត់បន្ថយការកាត់ទោសដោយសារតែការឃុំឃាំងមិនស្របច្បាប់ពីមុនរបស់ ឌុច នៅក្នុងតុលាការយោធា ។ នេះអាចក្លាយជាការកាត់ទោសមួយដែលតុលាការនឹងមានមោទនៈភាព ។ វីលៀម ស្មីត បានធ្វើសេចក្ដីសន្និដ្ឋានថា «ដើម្បីការគោរពចំពោះជនរងគ្រោះ ប្រជាជនកម្ពុជា និងសម្រាប់សន្តិភាពដោយគ្មានយុត្តិធម៌ យើងត្រូវតែចងចាំជនរងគ្រោះនិងផ្ញើរជូនអត្ថន័យដ៏មានន័យនេះទៅកាន់ប្រទេសកម្ពុជា» ។ក្រោយមកលោកក៏បានអង្គុយចុះ ។

ប្រធានចៅក្រម និល ណុន បានដកស្រង់យកសំណូមពររបស់ វីលៀម ស្មីត សម្រាប់ការបញ្ជាក់ពីការស្នើសុំរបស់ជនត្រូវចោទ និងសម្រាប់ការបញ្ជាក់ថាតើមេធាវីការពារក្ដីកំពុងតែធ្វើតាមសេចក្ដីបង្គាប់បញ្ជារបស់ជនត្រូវចោទដែលឬយ៉ាងណា ។ លោកប្រធាន បានសួរទៅកាន់ជនត្រូវចោទថាមានបំណងចង់និយាយជាលើកចុងក្រោយដែរឬទេ ។ ប្រសិនបើមាន ចៅក្រមនឹងបន្ថែមពេលវេលាសម្រាប់ជនត្រូវចោទ ។ ដោយសារតែចៅក្រមមិនទាន់យល់ច្បាស់ពីភាពមិនស៊ីចង្វាក់គ្នានៃសេចក្ដីថ្លែងការរបស់មេធាវីការពារក្ដី ចៅក្រមបានរំពឹងទុកថាបញ្ហានេះនឹងត្រូវបញ្ជាក់នៅក្នុងសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ។

## សេចក្ដីជំទាស់របស់មេធាវីការពារក្ដីជាតិ កា សាវុធ

មេធាវីការពារក្ដីជាតិ កា សាវុធ បានក្រោកឈរមានមតិយោបល់ពីសេចក្ដីជំទាស់របស់ខ្លួន ។ លោកបាននិយាយថា លោកមិនចង់ធ្វើការជំទាស់ទេ ប៉ុន្តែក្រោយមកលោកក៏បានជំទាស់នឹងការពង្រីកអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦សម្រាប់រយៈពេល៣០ឆ្នាំបន្ថែម ។ កា សាវុធ បានសង្កត់ធ្ងន់ថា អាជ្ញាយុកាលបានផុតសពុលភាពនៅឆ្នាំ១៩៨៩មកម្ល៉េះ ។ «នេះគឺវាហាក់បីដូចជាធ្វើឲ្យមនុស្សម្នាក់ស្លាប់ហើយឲ្យរស់ឡើងវិញ ដែលធ្វើបែបនេះ គឺជាអ្វីដែលមិនអាចកើតឡើងបានទេ» ។ លោកបានផ្ដល់ជាការពន្យល់បកស្រាយពីការជំទាស់នឹងការពង្រីកអាជ្ញាយុកាល ដែលមានភាពស្មុគស្មាញនិងពិបាកយល់ ដោយមានការទាញយកព័ត៌មានផ្សេងៗរួមមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៧១ មកបញ្ជាក់ជូនជាដើម ។

កា សាវុធ បាននិយាយពីមូលន័យសំខាន់នៃភាពអយុត្តិធម៌ ដោយលើកឡើងថាប្រធានគុក១៩៥ដទៃទៀតនៅក្នុងប្រទេសកម្ពុជាអំឡុងរបប ប៉ុល ពត មិនទាន់បាននាំមកកាត់ទោសស្វែងរកយុត្តិធ៌នៅឡើយទេ ។ មនុស្សជាច្រើនបានស្លាប់នៅក្នុងអគារគុកផ្សេងៗទាំងនោះ ។ «ចុះហេតុអ្វីបានជាមន្ទីរស-២១គឺជាគោលដៅសំខាន់សម្រាប់ការកាត់ទោសទៅវិញ?» កា សាវុធ បានចោទសួរ ។ សុន សេន គឺជាអ្នកគ្រប់គ្រងត្រួតពិនិត្យមន្ទីរស-២១ ចំណែកឯសមាជិកគណៈកម្មាអចិន្ត្រៃយ៍ដទៃគ្រប់គ្រងគុកផ្សេងៗទៀត ។ កា សាវុធ បានប្រកាសថា «យើងសូមបដិសេធថា មន្ទីរស-២១មិនមែនមានភាពខុសប្លែកតែឯងនោះទេ» ។ លោកបាននិយាយថា គោលបំណងនៃការកាត់ទោស មិនគួរធ្វើការស្វែងរកយុត្តិធម៌ឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបាន«កម្ទេច»នៅមន្ទីរស-២១ទេ ប៉ុន្តែព្រះរាជអាជ្ញាគួរតែស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះសួគត្រង់ដែលស្លាប់នៅក្នុងគុកដទៃទៀតនោះទៅវិញទេ ។

កា សាវុធ បាននិយាយថាជនត្រូវចោទ បានទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួនដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ។ លោកនិយាយថា ជនត្រូវចោទក៏បានបញ្ជាក់ជូនដូច្នេះដែរ ។ ប៉ុន្តែនរណាគឺ ជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ? «បក្សកុម្មុយនីស្តកម្ពុជា គឺគ្រាន់តែទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មបែបនោះតែប៉ុណ្ណោះ» លោកបានអះអាង ។ បក្សកុម្មុយនីស្តកម្ពុជា គឺស្ថិតនៅពីក្រោយការបញ្ជាសម្លាប់ទាំងអស់នេះ ។ ឌុច មិនបានចេញបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ។ កា សាវុធ បាននិយាយថា ឌុច គឺជាអ្នករងកំហុសជំនួសអ្នកដទៃ ។ ឌុច ត្រូវបានឃុំឃាំងអស់រយៈពេល១០ឆ្នាំ ប៉ុន្តែប្រធានគុកដទៃទៀតមិនត្រូវបានជាប់ឃុំឃាំងអ្វីឡើយ ។ «ដូច្នេះ សូមឲ្យកូនក្តីរបស់ខ្ញុំត្រឡប់ទៅផ្ទះផង ។ សូមដោះលែងគេ និងឲ្យគេវិលត្រឡប់ទៅផ្ទះវិញចុះ!» ។

## សេចក្តីជំទាស់របស់មេធាវីការពារក្តីអន្តរជាតិ ហ្រ្វង់ស្វ័រ រូ

មេធាវីការពារក្តីអន្តរជាតិ ហ្រ្វង់ស្វ័រ រូ បានបន្តសេចក្តីជំទាស់របស់ខ្លួនពីចំណុចនេះ ។ លោកបាននិយាយជាចំពោះទៅកាន់ វីលៀម ស្មិត : «អ្នកបានជំទាស់ជាមួយនឹងពាក្យសម្តីរបស់ខ្ញុំកាលពីម្សិលមិញ» ។ បន្ទាប់មក ហ្រ្វង់ស្វ័រ រូ បានព្យាយាមធ្វើឲ្យចំណុចសំខាន់របស់ វីលៀម ស្មិត មិនមានសារសំខាន់ ដោយនិយាយថា ព្រះរាជអាជ្ញាបានទទួលស្គាល់ការនិយាយពីទំនួលខុសត្រូវផ្ទាល់របស់ ឌុច និងការសហការរបស់ ឌុច ជាមួយនឹងតុលាការ ។ ហ្រ្វង់ស្វ័រ រូ បានអះអាងថា ការទទួលស្គាល់របស់ព្រះរាជអាជ្ញាមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ។ ជាមួយគ្នានេះ លោកក៏បានការពារសេចក្តីសន្និដ្ឋានសង្ខេបចំនួន១៦ទំព័ររបស់ខ្លួន ។ «ជនត្រូវចោទបានព្យាយាមសម្របសម្រួលខ្លួនចូលទៅក្នុង

ប្រព័ន្ធច្បាប់ បើយោងតាមពាក្យសម្ដីដែលជនត្រូវចោទបាននិយាយតាំងពីឆ្នាំ១៩៩៩ ដែលថាខ្លួនទទួលស្គាល់ខក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ ឌុច បាននិយាយថា "ខ្ញុំទទួលស្គាល់ខក្រដ្ឋិកម្មរបស់ខ្ញុំ ខ្ញុំសូមសុំទោសទៅកាន់ជនរងគ្រោះទាំងអស់ ។ ជាមួយគ្នានេះ ខ្ញុំក៏មានទំនួលខុសត្រូវតាមក្រមសីលធម៌ សម្រាប់ខក្រិដ្ឋកម្មទាំងអស់ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជាដោយសារតែបក្សកុម្មុយនីស្តកម្ពុជា ពីព្រោះថាខ្ញុំគឺជាសមាជិកម្នាក់របស់បក្សនេះ" ។

អ៊ីគ្រៀរ

ហ្វ្រង់ស៊័រ រូ បានធ្វើការជំទាស់នឹងការខិតខំប្រៀបធៀបភាពខុសគ្នានៃរឿងក្ដីរបស់ Ordemovic នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ "មនុស្សដែលត្រូវបានសម្លាប់នៅក្នុងរយៈពេលតែបីថ្ងៃ គឺត្រូវបានសម្លាប់រង្គាល់ដោយសារតែ Ordemovic ដែលជួយនឹងអ៊ីដែលថា មនុស្សទាំងអស់នោះគួរតែត្រូវបានការពារដោយសារ Ordemovic" ។ ហ្វ្រង់ស៊័រ រូ បានលើកឡើងពីជនត្រូវចោទ អាល់ប៊ឺត ស្ពៀរ ហើយនិយាយថា ទោះបីជា ស្ពៀរ បានជួយរារាំង អ៊ីគ្លែរ មិនឲ្យសម្រេចគោលនយោបាយបំផ្លិចបំផ្លាញនេះដោយផ្នែកក៏ដោយ ក៏ ស្ពៀរ នៅតែមានទំនួលខុសត្រូវនៅក្នុងបក្សណាស៊ី អាឡឺម៉ង់ ខ្ពស់ជាង ឌុច នៅក្នុងរបប ប៉ុល ពត ដែរ ។ ហ្វ្រង់ស៊័រ រូ បាននិយាយថា "ខក្រិដ្ឋកម្មរបស់ ស្ពៀរ មានលក្ខណៈធ្ងន់ធ្ងរជាងនេះរាប់ពាន់ដង" ។ ដោយសារតែលក្ខណៈធ្ងន់ធ្ងរនៃខក្រិដ្ឋកម្មទាំងអស់នេះហើយ ទើបតុលាការកាត់ទោសនួរឹមប៊ឺក បានទទួលយកការទទួលស្គាល់កំហុសរបស់ ស្ពៀរ ។ តើព្រះរាជអាជ្ញានៅទីនេះអាចនិយាយថា ឌុច បានគ្រប់គ្រងរបបនៃអំពើព្រៃផ្សៃនៅក្នុងប្រទេសកម្ពុជាបានដោយរបៀបណាទៅ? ហ្វ្រង់ស៊័រ រូ បានអះអាងថា បើទោះបីជាអ្នកទោសចំនួន១២,៣៨០នាក់បានស្លាប់នៅមន្ទីរស-២១ដូចដែលព្រះរាជអាជ្ញាចោទប្រកាន់ ឌុច ពីការស្លាប់ទាំងអស់នោះក៏ដោយ ក៏ការស្លាប់ទាំងនោះ មិនបានបង្កឲ្យមានអំឡុងពេលនៃអំពើព្រៃផ្សៃ ដើម្បីប្រតិបត្តិដំណើរការរបបរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាឡើយ ។

ទាក់ទិននឹងទំនាក់ទំនងរបស់ ឌុច ជាមួយនឹង សុន សេន, ហ្វ្រង់ស៊័រ រូ បាននិយាយថា ដើម្បីមានជំនឿទុកចិត្តទៅលើ សុន សេន, ឌុច ត្រូវតែស្វែងយល់ថា សុន សេន គឺជាមនុស្សដូចម្ដេច ។ លោកបានអះអាងថា សុន សេន គួរតែនាំមកកាត់ទោសនៅក្នុងតុលាការនេះ ។ (បើទោះបី ជា សុន សេន បានស្លាប់យ៉ាងពិតប្រាកដហើយក៏ដោយនោះ) ។ សុន សេន គឺជាមនុស្សរបស់បក្សកុម្មុយនីស្ត

កម្ពុជា ហើយ ឌុច បានធ្វើតាមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ។ ហ្វ្រង់ស្វ័រ រូ បាននិយាយថា ឌុច គឺជាមនុស្សសោកនាដកម្ម “បាទ! ប្រាកដណាស់ គឺសោកនាដកម្ម” ។

បន្ទាប់មក ហ្វ្រង់ស្វ័រ រូ បានបង្កើតសេចក្តីជំទាស់ថ្មីមួយទៀត ។ “ប្រសិនបើ ឌុច បានលាលែងឈប់ធ្វើការនៅមន្ទីរស-២១ តើអ្នកជឿថាមន្ទីរនេះនឹងនៅតែមានដំណើរការទៅមុខទៀតដែរឬទេ? ច្បាស់ជាមានដំណើរទៅមុខ ហើយវានឹងក្លាយទៅជាម៉ាស៊ីនសម្លាប់មនុស្សដែលស្ថិតនៅក្នុងដៃរបស់ សុន សេន ។ ឌុច មានភាពវង្វេងវង្វាន់ដោយសារតែ ឌុច បានជឿជាក់លើបដិវត្តន៍ដែលថាបដិវត្តន៍ គឺល្អសម្រាប់ប្រជាជនរបស់ខ្លួន” ។

ហ្វ្រង់ស្វ័រ រូ បានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានទទួលស្គាល់ថាមានលក្ខខ័ណ្ឌសម្រាលទោស ។ លោកបានអះអាងថា ឌុច ត្រូវតែទទួលបានអត្ថប្រយោជន៍ពីលក្ខខ័ណ្ឌសម្រាល ទោសនេះ ។ ទីមួយ បើយោងតាមការបង្ខិតបង្ខំ និងបញ្ជាថ្នាក់លើ ៖ ឌុច មិនបានចាកចេញពីប្រព័ន្ធនេះទេ ។ អ្នកគ្រប់គ្នានៅក្នុងប្រព័ន្ធបក្សនេះ ទទួលបញ្ជាពីថ្នាក់លើរបស់គេ និងចេញបញ្ជាបន្តទៅឲ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួន ។ សេចក្តីសម្រេចកាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ បានកំណត់គោលនយោបាយទាំងស្រុងមួយនៃការកម្ចាត់ខ្មាំងរបស់បដិវត្តន៍ ។ គណៈកម្មាធិការអចិន្ត្រៃយ៍ជាអ្នកចេញសេចក្តីសម្រេចដូច្នោះ មិនមែន ឌុច ទេ ។ ការគេចខ្លួនមិនអាចធ្វើទៅរួចបានទេ ។ ទីពីរ សហព្រះរាជអាជ្ញាមិនបានជំទាស់នឹងការសហការរបស់ ឌុច ទេ ។ ទីបី ឌុច បានបង្ហាញពីវិប្បដិសារី និងការស្គាល់កំហុសជាច្រើនលើកច្រើនសារមកហើយ ហើយ ឌុច ក៏បានសុំឲ្យទុកទ្វារនៃការអត់ឱនទោសនៅចំហរ ។ ទីបួន យើងត្រូវតែពិចារណាទៅលើបុគ្គលិកលក្ខណៈរបស់ ឌុច ។ ទីប្រាំ មានបញ្ហាមួយដែលអ្នកចិត្តសាស្ត្របានកត់សម្គាល់ចំពោះបុគ្គលិកលក្ខណៈរបស់ ឌុច ។ ក្នុងអំឡុងពេលមួយឆ្នាំនេះ អ្នកចិត្តសាស្ត្រទាំងនោះបានឃើញមានការប្រែប្រួលនៅក្នុងការវិវត្តន៍ផ្នែកចិត្តសាស្ត្ររបស់ ឌុច ។ តើ ឌុច គឺជាមនុស្សព្រៃផ្សៃក្នុងរបប ប៉ុល ពត ឬ? ហ្វ្រង់ស្វ័រ រូ បានរៀបរាប់ថា មុននឹងប្រព្រឹត្តអំពើព្រៃផ្សៃទៅលើជនរងគ្រោះ អ្នកសម្លាប់មនុស្សបានធ្វើឲ្យខ្លួនឯងមានភាពព្រៃផ្សៃរួចជាស្រេចទៅហើយ ។ “គ្មានមនុស្សណាម្នាក់ដែលកើតមកជាអ្នកសម្លាប់មនុស្សទេ មនុស្សនោះគឺក្លាយជាអ្នកសម្លាប់មនុស្សដោយខ្លួនឯង” ។

ហ្វ្រង់ស្វ័រ រូ បាននិយាយពីច្បាប់កាត់ទោសរបស់ប្រទេសហូល្លង់ ដែលទាមទារឲ្យមានការពិចារណាអំពីទស្សនៈនៃយុត្តិធម៌តាមបែបផ្សះផ្សារ ៖ ការសុំទោស ការទទួលស្គាល់កំហុសនិងអត្តចរិករបស់ជន

ត្រូវចោទ។ លោកបាននិយាយថា គ្មានយុត្តិធម៌ទេ ប្រសិនបើគោលបំណងនៃការកាត់ទោស គឺដើម្បីដាក់ទណ្ឌកម្ម។ លោកបានបន្តទៀតថា ការកាត់ទោសនឹងមិនអាចផ្សះផ្សារទុក្ខវេទនារបស់ជនរងគ្រោះបានទេ។ ប៉ុន្តែយើងមិនត្រូវយកភ្នែកសងដោយភ្នែក ធ្មេញសងដោយធ្មេញនោះទេ។ យើងសូមសំណូមពរឲ្យចៅក្រមពិចារណាពីក្រមព្រហ្មទណ្ឌថ្មីដែលនឹងកើតឡើងនៅពេលឆាប់ៗនេះ និងសំណងជួសជុលខូចខាតដែល ឌុច មានសិទ្ធិទទួលបានសម្រាប់ការរំលោភលើសិទ្ធិរបស់ ឌុច គឺការឃុំឃាំងដោយខុសច្បាប់នៅក្នុងតុលាការយោធា។ «មានមនុស្សជាច្រើនទៀតដែលមានទំនួលខុសត្រូវជាង ឌុច ដែលមិនបានកាត់ទោស។ ឌុច បានចំណាយពេល១០ឆ្នាំ នៅក្នុងមន្ទីរឃុំឃាំងរួចទៅហើយ។ ហ្វ្រង់ស្វ័រ រូ បាននិយាយថា អ្នកមិនអាចទាញយកភាព ជាប់ពាក់ព័ន្ធគ្នារវាងប្រធានគុកដទៃទៀត និងមេដឹកនាំថ្នាក់ខ្ពស់ដែលមិនទាន់បានកាត់ទោសទាំងនោះឡើយ។

ហ្វ្រង់ស្វ័រ រូ បានសង្កត់ធ្ងន់ថា ច្បាប់លើកលែងទោសឆ្នាំ១៩៩៤ បានបញ្ចប់សង្គ្រាមស៊ីវិល និងត្រូវបានតាក់តែងឡើងដើម្បីបង្កើតសន្តិភាពជាមួយនឹងខ្មាំង។ លោកបានសុំឲ្យតុលាការធ្វើការពិចារណាចំពោះចំណុចនេះឡើងវិញ និងសុំកុំឲ្យតុលាការប្រែក្លាយ ឌុច ឲ្យទៅជាមនុស្ស ដែលរងកំហុសជំនួសអ្នកដទៃ។ លោកបានក្រើនរំលឹកចៅក្រមថា លោកបានអះអាងថា ឌុច បានស្លាប់បាត់ហើយកាលពីថ្ងៃព្រហស្បតិ៍នៅក្នុងថ្ងៃបញ្ចប់ការសួរដេញដោល។ លោកបានបញ្ជាក់ថា ឌុច គឺស្លាប់ហើយ ហើយឥឡូវនេះតុលាការកំពុងតែនៅប្រឈមមុខជាមួយនឹងអតីតគ្រូគណិតវិទ្យាមួយរូបទេ។

## វីលៀម ស្មីត និង ហ្វ្រង់ស្វ័រ រូ ជំទាស់គ្នាទៅវិញទៅមក

វីលៀម ស្មីត បានក្រោកឈរមានមតិយោបល់នៅពេលសេចក្តីជំទាស់របស់ ហ្វ្រង់ស្វ័រ រូ បានបញ្ចប់។ លោកបាននិយាយថា «ប្រហែលនេះគឺជាការធ្វេសប្រហែសមួយ ប៉ុន្តែមេធាវីការពារក្តី បានគេចវេសមិនឆ្លើយនឹងសំណួររបស់អ្នកដោយផ្ទុរទៅជាការស្នើសុំរបស់ជនត្រូវចោទទៅវិញទេ»។ លោកបានបន្តទៀតថា ៖ «តើជនត្រូវចោទកំពុងតែសុំការសម្រាលទោស ឬការសុំឲ្យរួចទោស? ហេតុអ្វីបានជាក្រុមមេធាវីការពារក្តីបានបង្កើតឲ្យមានសេចក្តីជំទាស់ការពារក្តីពីរស្របពេលគ្នាដូច្នេះទៅវិញ? តើអ្វីគឺជាមូលដ្ឋានសម្រាប់ការឲ្យរួចទោស? ជនរងគ្រោះនឹងគ្មានភាពធូរស្បើយទេ ប្រសិនបើជនត្រូវចោទគ្រាន់តែមានទំនួលខុសត្រូវជាលក្ខណៈទូទៅ ប៉ុន្តែមិនមែនទំនួលខុសត្រូវតាមផ្លូវច្បាប់។ ដោយសារតែការគេចវេសនេះ ដូច្នេះអ្វីដែលប្រសើរជាងនេះនោះ គឺត្រូវតែសួរទៅកាន់ជនត្រូវចោទថាតើខ្លួនបានបន្តាប់

មេធាវីការពារក្ដីពីមូលដ្ឋានពីរខុសគ្នាដែលមិនមែនជាការសហការ និងវិប្បដិសារីដ៏ពិតប្រាកដនោះមែន ដែរឬទេ ។ ប្រសិនបើសំណូមពររបស់ជនត្រូវចោទគឺជាការសុំឲ្យរួចទោស នោះវានឹងប៉ះពាល់ដល់ការសុំ ទទួលស្គាល់ពីវិប្បដិសារី ហើយវានឹងនាំមកនូវការកាត់ទោសដែលមានរយៈពេលវែងជាងនេះ ។ ប្រសិន បើមេធាវីការពារក្ដីមិនបានធ្វើតាមការបង្គាប់បញ្ជារបស់ ឌុច ទេ នោះតុលាការត្រូវបានរំពឹងទុកជាមុន ពីអាទិភាពនៃការស្នើសុំដោយ ឌុច ដោយផ្អែកលើមូលហេតុដែលថាមេធាវីការពារក្ដីមិនបានគោរពតាម ការបង្គាប់បញ្ជារបស់ខ្លួន ។

ហ្វ្រង់ស្វ័រ រូ បានបដិសេធទៅនឹងអ្វីដែល វីលៀម ស្មីត បានកំពុងនឹងលើកឡើងដោយសារតែគ្មានបទ បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង ចែងពីការជំទាស់ទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីឡើយ ។ បន្ទាប់មក ហ្វ្រស់ស្វ័រ រូ បានចាប់ផ្ដើមមានភាពខឹងសម្បា និងប្រមាថ ។ លោកបាននិយាយថា សហព្រះរាជអាជ្ញា“ច្បាស់ជាមិនបានស្ដាប់យើងនិយាយនោះទេ ។ ពាក្យ“សុំឲ្យរួចទោស” មិនត្រូវបាន ប្រើប្រាស់ទេនាពេលព្រឹកនេះ ។ មេធាវីការពារក្ដីទាំងពីរបានជម្រុញឲ្យមានការសម្រាលទោសដែលថា ឌុច គួរតែត្រូវបានដោះលែងឲ្យបានឆាប់តាមតែអាចធ្វើបាន ។ ឌុច គួរតែត្រូវបានដោះលែងឲ្យ មានសេរីភាពបន្ទាប់ពីបានជាប់ឃុំឃាំងអស់រយៈពេល១០ឆ្នាំ និងបន្ទាប់ពីបានទទួលស្គាល់ឧក្រិដ្ឋកម្មទាំង នេះ” ។ យ៉ាងណាមិញ ចៅក្រមនៅតែមានភាពច្របូកច្របល់ ហើយបន្តិចក្រោយមក ហ្វ្រង់ស្វ័រ រូ ត្រូវបានជំទាស់ដោយសហមេធាវីរបស់ខ្លួន កា សាវុធ ។

## ការប្រកួតប្រជែងត្រូវបានបញ្ចប់ដោយ ឌុច

ភាពច្របូកច្របល់កាន់តែខ្លាំងបានបន្តកើតមានឡើងនៅក្នុងបន្ទប់សវនាការ ។ ចៅក្រមបានប្រឹក្សាជា មួយគ្នា ។ ជាចុងក្រោយ ប្រធានចៅក្រម និល ណុន បានសួរថា “តើជនត្រូវចោទមានបំណងចង់ និយាយដែរឬទេ”? វាមានភាពមិនច្បាស់លាស់នៅឡើយសម្រាប់មតិយោបល់របស់មេធាវីការពារ ក្ដីរបស់ជនត្រូវចោទ ។ ចៅក្រមរំពឹងឲ្យជនត្រូវចោទបញ្ជាក់ពីគោលជំហររបស់ខ្លួន ។ សំណួររបស់យើង មិនទាន់បានឆ្លើយតបមកវិញឲ្យបានក្បោះក្បាយនៅឡើយទេ ។ ចៅក្រម និងសាធារណៈជនបានតាម ដាននូវការចង់ចាំដ៏ល្អរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។ យើងចង់ស្ដាប់ពីគោលជំហរផ្ទាល់ខ្លួន របស់ជនត្រូវចោទ” ។

ឌុច បានក្រោកឈរឡើងហើយនិយាយដូចខាងក្រោម ៖ «ខ្ញុំសូមថ្លែងអំណរគុណសម្រាប់ឱកាស ដើម្បីនិយាយជាលើកចុងក្រោយ ។ ខ្ញុំបានធ្វើការដោយឆន្ទៈសហការជាមួយនឹងតុលាការ ។ ចាប់តាំងពីការចាប់ខ្លួនរបស់ខ្ញុំកាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៩៩ ទៅកាន់តុលាការយោធាមក ខ្ញុំបានតាំងចិត្តថានឹងរាយការណ៍ជូនតុលាការដោយស្មោះត្រង់ និងឥតលាក់លៀមឡើយ ។ ខ្ញុំបានសហការដោយឆ្លើយតបនឹងសំណួរទាំងអស់របស់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ។ ខ្ញុំបានឆ្លើយតបនឹងសំណួរនៅក្នុងដំណើរការនីតិវិធីទាំងអស់នេះយ៉ាងពេញលេញ ។ ភស្តុតាងគឺមាននៅក្នុងប្រតិចារឹក ។ នៅក្នុងកថាខណ្ឌទី៨៦ នៃការដាក់សេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំបានពិចារណាពីឧក្រិដ្ឋកម្ម ដែលកើតឡើងនៅមន្ទីរស-២១ និងមិននិយាយពីឧក្រិដ្ឋកម្មទាំងនោះតទៅទៀតនោះទេ ។ ខ្ញុំសូមសំណូមពរឲ្យចៅក្រមធ្វើការពិចារណាចំពោះអ្វីដែលខ្ញុំបាននិយាយ ។ ឯកសារចំនួន៣៣ទំព័ររបស់ខ្ញុំ គឺគ្រាន់តែជាផ្នែកមួយតូចនៃព័ត៌មានដែលខ្ញុំបានផ្ដល់ឲ្យតែប៉ុណ្ណោះ ។ ខ្ញុំបានសហការយ៉ាងពេញទំហឹងគ្រប់កាលៈទេសៈទាំងអស់របស់តុលាការនេះ ។

«ខ្ញុំបានសម្ដែងពីការសុំទោស និងការទទួលស្គាល់កំហុសរបស់ខ្ញុំ ។ តុលាការនេះមានយុត្តាធិការចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ មន្ទីរម-១៣ ក៏ត្រូវបានពិភាក្សាហើយខ្ញុំក៏បានឆ្លើយតបនឹងសំណួរអំពីមន្ទីរម-១៣ដែរ ។ ជាមួយគ្នានេះ ខ្ញុំក៏ត្រូវបានសួរពីព្រឹត្តិការណ៍ដែលកើតឡើងក្រោយពីឆ្នាំ១៩៧៩ ។ ខ្ញុំមិនដែលបំភ្លេចនូវព្រលឹងមនុស្សចំនួនមួយលាននាក់ដែលត្រូវបានសម្លាប់រួមទាំងសាច់ញាតិរបស់ខ្ញុំ ។ ប៉ុន្តែ ឧក្រិដ្ឋកម្មទាំងអស់ គឺត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងនាមជាសមាជិកម្នាក់របស់បក្ស ខ្ញុំសូមទទួលស្គាល់ និងសូមទោស ។ ប៉ុល ពត ពឹងផ្អែកលើបក្សយ៉ាងខ្លាំង ហើយខ្ញុំគឺជាសមាជិករបស់បក្ស» ។

«ខ្ញុំសូមមិនជិតាស់នឹងការស្លាប់របស់មនុស្សចំនួន ១២,៣៨០ នាក់នៅមន្ទីរស-២១ឡើយ ។ ខ្ញុំសូមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះដោយគ្មានការបដិសេធអ្វីឡើយ ។ ខ្ញុំសូមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្នុងនាមជាអ្នករួមចំណែកនៅក្នុងបក្សឧក្រិដ្ឋកម្មនេះ ។ ខ្ញុំសូមទទួលស្គាល់ថាមនុស្សទាំងនេះបានស្លាប់នៅក្នុងមន្ទីរស-២១ ។ អនុប្រធានរងរបស់ខ្ញុំគឺ ហ៊ឹរ ទទួលបន្ទុកខាងសម្លាប់ ។ ខ្ញុំមិនចង់ឲ្យ ហ៊ឹរ មានទំនួលខុសត្រូវទាំងអស់នេះទេ ។ ខ្ញុំបានទទួលការអប់រំពីអ្នកចិត្តសាស្ត្រថា ខ្ញុំត្រូវតែធ្វើការផ្សះផ្សារពីអត្តន័យនៃភាពជាមនុស្ស ។

បន្ទាប់មក ឌុច បានបន្តអះអាងថា ខ្លួនមិនមែនជាអ្នកដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមនោះទេ និងបានចង្អុលបង្ហាញពីបុគ្គលប្រាំមួយរូបនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលបានបំពេញទៅតាមតម្រូវការរបស់បក្ស ។ ក្រោយមក ឌុច បាននិយាយថា គ្មាននរណាម្នាក់អាចរំលោភមាគ៌ាបក្សបានឡើយ ។ ប៉ុល ពត គឺជាអ្នកគ្រប់គ្រងដែលទទួលបន្ទុកនៅក្នុងបក្ស ។ ឌុច បានបន្តទៀតថា អ្នកគ្រប់គ្រងនៅតាមភូមិភាគមានអំណាចក្នុងការ“កម្ទេច” ។ ប្រសិនបើអ្នកទាំងនោះរំលោភលើឆន្ទៈនៃសមូហភាព ពួកគេក៏ត្រូវតែ“កម្ទេច”ដែរ ។ គោលបំណងនៃច្បាប់របស់ អ.វ.ត.ក គឺធ្វើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ដែលអាចនាំមកនូវយុត្តិធម៌ជូនដល់អ្នកគ្រប់គ្នា នៅក្នុងប្រទេស និងដើម្បីទទួលបាននូវការផ្សះផ្សារជាតិ ។

ប៉ុន្តែ ឌុច បានបន្តទៀតថា ៖ “ខ្ញុំមិនដែលជំទាស់នឹងឧក្រិដ្ឋកម្មដែលកើតមានឡើងនៅមន្ទីរស-២១ទេ ។ ខ្ញុំបានធ្វើការនៅទីនោះអស់រយៈពេល១០ឆ្នាំ ៦ខែ និង ១៨ថ្ងៃ ។ ខ្ញុំមិនជំទាស់ថា ការជាប់ឃុំឃាំងរបស់ខ្ញុំគឺជាការខុសច្បាប់នោះទេ ។ ខ្ញុំបានចាកចេញមករកតុលាការនេះ ដើម្បីកំណត់ពីភាពខុសច្បាប់នោះ ។ ខ្ញុំសូមសុំឲ្យចៅក្រមដោះលែងខ្ញុំ” ។

ប្រធានចៅក្រម និល ណុន បានសួរទៅកាន់ជនត្រូវចោទឲ្យក្រោកឈរ និងនិយាយទៅកាន់ចៅក្រមម្តងទៀត “ចៅក្រមបានស្តាប់ពុការនិយាយជាលើកចុងក្រោយរបស់អ្នក ។ អ្នកសុំឲ្យដោះលែងអ្នក ។ ឥឡូវនេះសំណួរគឺថា តើអ្វីដែលធ្វើឲ្យអ្នកសុំឲ្យមានការដោះលែងខ្លួន ។ តើអ្នកកំពុងតែសុំឲ្យរួចទោសពីការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នក ឬក៏សុំការសម្រាលទោសដោយសារការសហការ និងរយៈពេលជាប់ឃុំឃាំងចាប់តាំងពីឆ្នាំ១៩៩៩នោះ? យើងត្រូវការភាពច្បាស់លាស់ដើម្បីធ្វើសេចក្តីសម្រេចរបស់យើង ។

ឌុច បានឆ្លើយតបថា “សមត្ថភាពរបស់ខ្ញុំក្នុងការវិភាគគឺមានព្រំដែនកំណត់ទៅនឹងអ្វីដែលខ្ញុំអាចរាយការណ៍បាន ។ ខ្ញុំសូមឲ្យតុលាការធ្វើការដោះលែងរូបខ្ញុំ” ។

ប្រធានចៅក្រម និល ណុន បានឆ្លើយទៅវិញថា “ដំណើរទៅមុខនេះ គឺមានលក្ខណៈប្លែកនៅទីបញ្ចប់នៃតុលាការកាត់ទោសនេះ បើប្រៀបធៀបទៅនឹងការអនុវត្តច្បាប់តាមថ្នាក់ជាតិ ។ ជនត្រូវចោទបាន

ចន្លុលបន្លាញឲ្យមេធាវីការពារក្តីជាតិរបស់ខ្លួននិយាយបន្តិចបន្តួច ។ ប្រហែលជាមេធាវីការពារក្តីជាតិអាចបញ្ជាក់ពីគោលជំហររបស់សហមេធាវីការពារក្តីបាន" ។

កា សាវុធ បានក្រោកឈរឡើង និងស្នើសុំឲ្យមានការដោះលែង ឌុច ។ លោកបានលើកឡើងម្តងទៀត ពីការអះអាងពីមុនរបស់លោកថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមនោះទេ ហើយ សុន សេន គឺជាអ្នកដែលមានអំណាចធ្វើការ"កម្ទេច" នៅឯមន្ទីរស-២១ ដោយសារតែ សុន សេន គឺជាសមាជិករបស់គណៈកម្មាធិការអចិន្រ្តៃយ៍និងអះអាងថា ឌុច មិនមែនជាជនដែលនៅក្នុងចំណោមជនដែលមានទំនួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្ម ដូច្នេះបក្សកុម្មុយនីស្តកម្ពុជា គឺជាជនល្មើស ។ ដោយសារតែហេតុផលទាំងនេះហើយ ទើបក្រុមមេធាវីការពារក្តីសុំឲ្យមានការដោះលែងជនត្រូវចោទ ។

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ បានមានមតិយោបល់ដោយសួរសំណួរនេះ ៖ "តើខ្ញុំអាចទាញន័យបានថា ជនត្រូវចោទកំពុងតែសុំឲ្យរួចទោសមែនដែរឬទេ" ?

កា សាវុធ បានឆ្លើយតបថា "ការដោះលែងមានន័យថា ការសុំឲ្យរួចទោស" ។

ប្រធានចៅក្រម និល ណុន បានប្រកាសសេចក្តីបញ្ចប់នៃតុលាការកាត់ទោសនេះ និងបានធ្វើសេចក្តីសង្ខេបពីព័ត៌មានសំខាន់ៗស្តីពីដំណើរការនីតិវិធីរបស់តុលាការកាត់ទោស ដែលមានរយៈពេលសរុប ៧៧ថ្ងៃ ។ លោកប្រធានបានថ្លែងអំណរគុណដល់អ្នកភាគីដែលបានចូលរួម រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ។ លោកបាននិយាយថា ចៅក្រមនឹងធ្វើការពិចារណាយ៉ាងល្អិតល្អន់ និងរៀបចំចេញសាលក្រមស្ថាពរ ។ លោកប្រធានបានបន្តទៀតថា កាលបរិច្ឆេទសម្រាប់សាលក្រមមិនអាចកំណត់បានទេ ដោយសារតែទំហំនៃសំណុំរឿង និងតម្រូវការដែលត្រូវធ្វើការសម្រេចនេះជាបីភាសា ។ យ៉ាងណាមិញ កាលបរិច្ឆេទសម្រាប់សាលក្រមនឹងប្រកាសជូនជាមុន ។

## សន្និសីទកាសែត

ភ្លាមៗនៅក្នុងបន្ទប់សន្និសីទកាសែតបន្ទាប់ពីដំណើរការនីតិវិធីពេញមួយថ្ងៃ សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត បាននិយាយថា ឌុច ត្រូវបានធ្វើជាតំណាងដោយមេធាវីការពារក្តី ដែលថាតុលាការ

កាត់ទោសនេះ គឺជាតុលាការប្រកបដោយយុត្តិធម៌ ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានធ្វើជាតំណាងដោយ ដោគជ័យ និងនិយាយថាអនុសាសន៍ដែលចៅក្រមរបស់តុលាការកាត់ទោសនេះធ្វើការទទួលបន្ទុកនៅក្នុងដំណើរការនីតិវិធី សន្និដ្ឋានថាជាតុលាការកាត់ទោសប្រកបដោយយុត្តិធម៌ ។ លោកបាននិយាយថា សហព្រះរាជអាជ្ញា មានការភ្ញាក់ផ្អើលនឹងយុត្តិសាស្ត្ររបស់ក្រុមមេធាវីការពារក្តីនៅក្នុងសប្តាហ៍នេះ ។ សំណូមពរសុំឲ្យរួចទោស បានឆ្លុះបញ្ចាំងពីទស្សនៈរបស់ជនត្រូវចោទពីអ្វីដែលគេចង់បាន ។ ជនត្រូវចោទបានបង្ហាញឲ្យឃើញពីវិប្បដិសារី និងការសហការខ្លះៗ ប៉ុន្តែវិប្បដិសារីនេះ គឺកំពុងតែមានព្រំដែនកំណត់ដោយសារតែការសុំឲ្យមានការរួចទោសរបស់ជនត្រូវចោទ ។

សហព្រះរាជអាជ្ញាជាតិ ជា លាង បាននិយាយថា ក្រុមរបស់លោកស្រីមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ឌុច បានសុំឲ្យមានការរួចទោសដែលនេះផ្ទុយពីអ្វីដែលមេធាវីការពារក្តីអន្តរជាតិ ហ្រ្វង់ស័រ រូ បានព្យាយាមធ្វើកន្លងមក គឺការទទួលស្គាល់កំហុស និងលក្ខខណ្ឌសម្រាលទោស “ប៉ុន្តែថ្ងៃនេះ យើងបានស្តាប់ព្ទនូវព័ត៌មានផ្ទុយគ្នា” ។ ដូច្នេះគោលជំហររបស់ក្រុមមេធាវីការពារក្តីគឺ មានភាពលាយឡំគ្នា ។ មេធាវីការពារក្តីជាតិបានសុំឲ្យមានការឲ្យរួចទោស និងការដោះលែង ។ ចំណែកឯមេធាវីការពារក្តីអន្តរជាតិមានទស្សនៈផ្សេង ។ ឌុច មានបំណងចង់ឲ្យការចោទប្រកាន់ត្រូវបានបោះបង់ចោល ។

វីលៀម ស្មីត បាននិយាយថាមេធាវីការពារក្តីទាំងពីរបានបញ្ចប់ការអះអាងរបស់ខ្លួន ដោយសុំឲ្យមានការដោះលែង ឌុច ។ ប្រហែលជាដើម្បីសម្រេចនូវភាពសមហេតុផលដែល ហ្រ្វង់ស័រ រូ បានបន្តធ្វើនោះ គឺត្រូវបានសន្និដ្ឋានដោយផ្អែកលើរយៈពេល១០ឆ្នាំដែលបានបំរើការសម្រាប់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ហើយដូច្នេះវាគួរតែគ្រប់គ្រាន់ហើយ ។ ដោយសារតែការមិនព្រមព្រៀងគ្នារវាងមេធាវីការពារក្តីទាំងពីរ ស្មីត ជឿថា ការបែងវំលែកទំនួលខុសត្រូវរបស់ក្រុមមេធាវីអាចប្រើការបានយ៉ាងល្អនៅក្នុងតុលាការនិងបានជួយអភិវឌ្ឍជំនាញទាំងនេះនៅក្នុងរឿងក្តីនាពេលអនាគតបាន ។ វីលៀម ស្មីត បានបន្តទៀតថា លោកមានការពេញចិត្តយ៉ាងខ្លាំងនៅពេលដែល ឌុច មិនដាក់បណ្តឹងឧទ្ធរណ៍ ។ “វាបានចំណាយពេលមួយរយៈកាល ដើម្បីទទួលបានចម្លើយនេះនៅក្នុងអង្គសវនាការ ។ ចម្លើយនោះវាបានធ្លាក់ទៅលើ ឌុច ដែលត្រូវបង្ហាញពីគោលជំហររបស់ខ្លួន ។ ចំណែកឯមេធាវីការពារក្តីបានបញ្ឈាក់អះអាងពីការសុំឲ្យមានការរួចទោស ។ ដោយសារតែមានការផ្តល់ដំបូន្មានរបស់មេធាវីការពារក្តី ហ្រ្វង់ស័រ រូ, ឌុច បាននិយាយថា ខ្លួនគ្មានទោស ហើយចង់បានលក្ខខណ្ឌសម្រាលទោស” ។

*វីលៀម ស្មីត បានពន្យល់ពីហេតុផលមួយចំនួននៃសំណូមពររបស់ព្រះរាជអាជ្ញា សម្រាប់ការកាត់ទោសដែលមានរយៈពេល៤០ឆ្នាំ និងបានប្រកាន់ខ្ជាប់នូវហេតុផលដូចគ្នា ដូចដែលលោកបានលើកឡើងនៅក្នុងអង្គសវនាការ ។ លោកបាននិយាយថា ការសហការរបស់ ឌុច នៅក្នុងតុលាការកាត់ទោសរឿងក្តីលេខ០០២ នឹងត្រូវយកមកពិចារណា ។ ការសហការមិនពេញលេញរបស់ ឌុច មានឥទ្ធិពលនៅក្នុងសេចក្តីស្នើសុំរបស់សហព្រះរាជអាជ្ញាក្នុងការកាត់បន្ថយរយៈពេល៥ឆ្នាំ ចេញពីការកាត់ទោសរយៈពេល៤៥ឆ្នាំ (ដូច្នេះការកាត់ទោសធ្លាក់មកនៅក្នុងរយៈពេលតែ៤០ឆ្នាំប៉ុណ្ណោះ) ។ ប៉ុន្តែ ឥឡូវនេះ «យើងនឹងមានការពិភាក្សាខ្លះៗនៅក្នុងការិយាល័យទាក់ទិននឹងបញ្ហាដែលយើងបានដឹងបន្ទាប់ពីមានការស្នើសុំឲ្យរួចទោស» ។*

*មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ការីម ខាន បាននិយាយនៅក្នុងសន្និសិទ្ធកាសែតថា វាគឺនៅតែជាថ្ងៃប្រវត្តិសាស្រ្តមួយសម្រាប់ថ្ងៃបញ្ចប់នៃតុលាការកាត់ទោសដំបូងបង្អស់ នៅចំពោះមុខអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វាគឺជាតុលាការកាត់ទោសកូនកាត់ ឬអន្តរជាតិដ៏ពេញលក្ខណៈដំបូងមួយដែលរួមមានការចូលរួមយ៉ាងសកម្មពីភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ លោកបាននិយាយថា ភាគីទាំងអស់មានភាពភ្ញាក់ផ្អើល ហើយវាមានលក្ខណៈខុសពីការរំពឹងទុកដែលថា ជនត្រូវចោទនឹងមិនដាក់ការឆ្លើយមិនមានទោស ។ «ឌុច កំពុងតែសុំការរួចទោស ។ ភាពប្រែប្រួលប្របល់នេះត្រូវតែធ្វើការសម្រុះសម្រួល.... ឌុច មានទំនួលខុសត្រូវលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ។ ឌុច បានលើកឡើងពីការការពារខ្លួនដោយផ្អែកលើយុត្តាធិការនាពេលចុងក្រោយនេះ ។ ដោយមិននិយាយពីទំនួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្ម ចាប់តាំងពីយុត្តាធិការផ្ទាល់របស់តុលាការមានជាប់ពាក់ព័ន្ធនឹងជនដែលទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មនោះមក ឌុច មិនបានចាប់ទុកខ្លួនឯងថាជាជន ដែលមានទំនួលខុសត្រូវខ្ពស់(ហើយ ឌុច ថែមទាំងបានបដិសេធថាខ្លួនមិនមែនជាមេដឹកនាំជាន់ខ្ពស់ទៀតផង)» ។ លោក ការីម ខាន់ បានបញ្ជាក់ថា ការអះអាងដូច្នេះ គឺជាពេលវេលាមួយដែលត្រូវបានរំពាងដោយវិធានផ្ទៃក្នុង ហេតុដូច្នេះហើយទើបមានយុត្តិសាស្រ្តជាច្រើននៅក្នុងបទព្រហ្មទណ្ឌអន្តរជាតិ និងតុលាការកូនកាត់នេះ ទៅលើពាក្យថា «មានទំនួលខុសត្រូវខ្ពស់» ដើម្បីបដិសេធលើការអះអាងរបស់ ឌុច ។ លោក ការីម ខាន់ បានបន្តទៀតថា «ឌុច បានបដិសេធមិនបង្ហាញពីការពិតពេញលេញទាក់ទិននឹងការខិតខំប្រឹងប្រែងរបស់ខ្លួននៅមន្ទីរស-២១ ។ ជាជាងធ្វើជាអ្នកចូលរួមដែលមានភាពស្ទាក់ ស្ទើរក្នុងការបំពេញភារកិច្ច ឌុច គឺជាអ្នកចូលរួមយ៉ាងសកម្មម្នាក់ ។ ឌុច បានទទួលរងគ្រោះនៅក្នុងបរិយាកាសទាំងមូលនៃរបប*

កម្ពុជាប្រជាធិបតេយ្យ ។ ការបដិសេធរបស់ឌុចដែលថា ឌុចគឺជាអ្នកចូលរួមដ៏មានភាពមោះមុតនោះ បានធ្វើឲ្យយើងមិនមានភាពជឿជាក់» ។